ធម្មនុញ្ញ Magna [(Magna Carta:MC)]

MC ឬអាចហៅថាជាធម្មនុញ្ញសំខាន់ (great charter)។ វាសេចក្តីថ្លែងការណ៍រវាង ស្តេច និង អភិជន (baron) អង់គ្លេស ដែលជាមូលដ្ឋាននៃសិទ្ធិធម្មនុញ្ញនៃអង់គ្លេសផងដែរ។ MC កម្រិតសិទ្ធិអំណាចដ៏ធំធេងរបស់ស្តេច និងកម្រិតផងដែរសកម្មភាព ដែលបំពានសិទ្ធិសេរីភាព។

បន្ថែមពីនេះ វាបានធ្វើឲ្យជាផ្លូវការ នូវនីតិវិធីតុលាការ និងច្បាប់ ព្រមទាំងនាំឲ្យមានទំនើបកម្មនៃច្បាប់ព្រហ្មទណ្ឌ សិទ្ធិសភាក្នុងការគ្រប់គ្រងពន្ធដារ។ MC បានផ្តល់ការប្តេជ្ញាចិត្ត ដល់ដំណើរការត្រឹមត្រូវ (due process) ជាមួយការធានាថា៖ *មិនមានបុគ្គលណា ត្រូវបានឃាត់ខ្លួន ឬ ដាក់ពន្ធនាគារ ឬ ដាក់ក្រៅច្បាប់ ឬ បណ្តេញចេញ ឬក្នុងទម្រង់ណាដែលក្លាយជាជនរងគ្រោះ ហើយមិនមានបុគ្គលណា ត្រូវបានគេវាយប្រហារ ឬបញ្ជាឲ្យគេវាយប្រហារគាត់ លើកលែងមានសាលក្រមស្របច្បាប់ ដោយសហការី ឬ តាមច្បាប់នៃប្រទេស*។[1]

ខ្លឹមសារនៃ MC ត្រូវបានកែសម្រួលបន្ថែមនៅចុងសតវត្សទី១៣ ដោយសភា និងដោយ Sir Edward Coke ដែលជាអ្នកផ្តើមទ្រឹស្តី Petition of Rights ដោយក្តោបវិសាលភាពលើបុគ្គលកាន់តែច្រើន និង មានលក្ខណៈជាច្បាប់ ជាជាងនយោបាយ (David Robertson, dictionary of human rights, 2004, 2nd Ed., pp. 152-153)។

[1] No free man shall be arrested or imprisoned or disseized or outlawed or exiled or in any way victimized, neither will we attack him or send anyone to attack him, except by the lawful judgement of his peers or by the law of the land.